**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........១១០៤..........**ក.ប**/គ.គ.ស

ថ្ងៃ ចន្ទ ១២ រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១៨

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជានាយក នាយិកា**

**នៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

**កម្មវត្ថុ** ៖ ការអនុញ្ញាតឲ្យសិស្ស-និស្សិតបានឈប់សម្រាកចំនួន៣ថ្ងៃ ដើម្បីចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦។

**យោង** ៖ អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងពិធីប្រគល់សញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជានាយកនាយិកា នៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទក្រសួងទាំងអស់ ជ្រាបថា ដើម្បីបង្កលក្ខណៈងាយស្រួលដល់សិស្ស-និស្សិតក្នុងការចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រីអនុញ្ញាតឲ្យសិស្ស-និស្សិតដែលកំពុងសិក្សានៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី បានឈប់សម្រាកចំនួន៣ថ្ងៃ គឺចាប់គិតពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជានាយកនាយិកា នៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាំងអស់ជ្រាប និងចាត់ចែងអនុវត្តការងារនេះឲ្យមានប្រសិទ្ធភាព។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- គ្រប់ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ